ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

*ថ្ងៃ អង្គារ ០៩ កើត ខែ ជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣*
*រាជធានីភ្នំពេញ, ថ្ងៃ ១១ ខែ មិថុនា ឆ្នាំ ២០១៩*

# សេចក្តីប្រកាសព័ត៌មាន
## កិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (គ.ស.ហ)

នាព្រឹកថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៩, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ) ដឹកនាំកិច្ចប្រជុំ គ.ស.ហ ដើម្បីពិនិត្យ និងពិភាក្សាលើរបៀបវារៈសំខាន់ៗចំនួនបី÷ ***"សេចក្តីព្រាងរបាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត ២០១៩ ស្តីពីការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាឆ្នាំ ២០១៦-២០៣០", "សេចក្តីព្រាងអនុក្រឹត្យស្តីពីការចុះបញ្ជីបរធនបាលកិច្ច"*** និង ***"សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិស្ថិរភាពហិរញ្ញវត្ថុកម្ពុជា"*** ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ និងថ្នាក់ដឹកនាំ ជាន់ខ្ពស់ក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ។

***១. សេចក្តីព្រាងរបាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត ២០១៩ ស្តីពីការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាឆ្នាំ ២០១៦-២០៣០÷***

***"សេចក្តីព្រាងរបាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្តឆ្នាំ ២០១៩"*** ជាឯកសារត្រួតពិនិត្យ និងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្ត "**គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក) ឆ្នាំ ២០១៦-២០៣០**" ដែលសម្រេចបានក្នុងរយៈពេល ៣ ឆ្នាំ កន្លងមក (២០១៦-២០១៨) តាមគោលការណ៍ស្ម័គ្រចិត្ត ។ របាយការណ៍នេះជាការចែករំលែកនូវបទពិសោធន៍នៃបណ្តាប្រទេសជាសមាជិករបស់អង្គការសហប្រជាជាតិលើភាពជោគជ័យ, បញ្ហាប្រឈម, មេរៀនដកស្រង់ពីការអនុវត្ត, និងគោលនយោបាយគន្លឹះក្នុងការជំរុញ និងពន្លឿនការអនុវត្តគោលដៅប្រកបដោចីរភាព ២០៣០ ។ ការចូលរួមក្នុងការត្រួតពិនិត្យវឌ្ឍនភាពគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព គឺឆ្លុះបញ្ចាំងពីកិច្ចខិតខំប្រឹងប្រែងរួមគ្នារវាងរដ្ឋាភិបាល និង តួអង្គពាក់ព័ន្ធ ជាពិសេស ដើម្បីសម្រេចនូវគោលដៅអភិវឌ្ឍន៍ "**គ្មាននរណាម្នាក់ត្រូវបានបំភ្លេចចោល**"។

កម្ពុជា គឺជាប្រទេសគំរូក្នុងចំណោមប្រទេសចំនួន ៦ ក្នុងពិភពលោក ដែលសម្រេចបានគោលដៅភាគច្រើននៃគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ និង ក្នុងចំណោមប្រទេសចំនួន ៥១ ដែលបានស្ម័គ្រចិត្តលើកទី ១ ក្នុងការបង្ហាញនូវវឌ្ឍនភាពនៃការអនុវត្ត **គ.អ.ច.ក** ព្រមទាំង ចែករំលែកនូវបទពិសោធន៍នៃភាពជោគជ័យ, បញ្ហាប្រឈម និងមេរៀនល្អៗដល់ប្រទេសដទៃទៀត ។ គួរបញ្ជាក់ថា បន្ទាប់ពីទទួលបានការឯកភាពក្នុងកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកសារនេះនឹងត្រូវដាក់ជូនដើម្បីទទួលការអនុម័តពីរាជរដ្ឋាភិបាលកម្ពុជា មុននឹងផ្ញើជូនអង្គការ

សហប្រជាជាតិ ក្នុងខែ មិថុនា ឆ្នាំ ២០១៩ ហើយនឹងត្រូវធ្វើបទបង្ហាញក្នុងវេទិកានយោបាយកម្រិតខ្ពស់របស់អង្គការសហប្រជាជាតិ ក្នុងអំឡុងខែ កក្កដា ឆ្នាំ ២០១៩ ខាងមុខនេះផងដែរ ។

***២. សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការចុះបញ្ជីបរធនបាលកិច្ច៖***

ការរៀបចំនូវ ***"សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការចុះបញ្ជីបរធនបាលកិច្ច"*** មានគោលបំណងកំណត់លក្ខខណ្ឌ និងនីតិវិធីលម្អិតនៃការចុះបញ្ជីបរធនបាលកិច្ច ដែលមាន ០៤ ប្រភេទ រួមមាន៖ បរធនបាលកិច្ចពាណិជ្ជកម្ម, បរធនបាល-កិច្ចសាធារណៈ, បរធនបាលកិច្ចសង្គម, និងបរធនបាលកិច្ចបុគ្គល ។

ការអនុម័តអនុក្រឹត្យនេះ នឹងចូលរួមចំណែកក្នុងការអនុវត្តច្បាប់ស្ដីពីបរធនបាលកិច្ច ក្នុងការជួយពង្រឹងដល់ការគ្រប់គ្រង និងការតាមដានត្រួតពិនិត្យវិស័យបរធនបាលកិច្ចប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ព្រមទាំង ជួយគាំទ្រដល់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជាប្រកបដោយបរិយាប័ន្ន ។

***៣. សេចក្ដីព្រាងព្រះរាជក្រឹត្យស្ដីពីការបង្កើតគណៈកម្មាធិការជាតិស្ថិរភាពហិរញ្ញវត្ថុកម្ពុជា៖***

ការបង្កើតយន្តការគ្រប់គ្រងស្ថិរភាពហិរញ្ញវត្ថុ គឺជានិន្នាការតំបន់ និង ពិភពលោក បន្ទាប់ពីវិបត្តិហិរញ្ញវត្ថុ ដែលបានកើតឡើងជាបន្តបន្ទាប់នាពេលកន្លងមក ។ ការបង្កើតយន្តការដើម្បីទប់ស្កាត់ និងគ្រប់គ្រងវិបត្តិហិរញ្ញវត្ថុ ឱ្យបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព គឺមានសារៈសំខាន់យ៉ាងខ្លាំងក្នុងការកាត់បន្ថយឥទ្ធិពលអវិជ្ជមានទៅលើវិស័យហិរញ្ញវត្ថុទាំងមូល និងការរាលដាលទៅកាន់វិស័យសេដ្ឋកិច្ចរូបវន្ត សំដៅធានាបាននូវស្ថិរភាព និងចីរភាពនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ។ សម្រាប់កម្ពុជា, ខណៈពេលដែលវិស័យហិរញ្ញវត្ថុកាន់តែមានការអភិវឌ្ឍ, ពិពិធកម្មទូលំទូលាយ និងសមាហរណកម្មស៊ីជម្រៅ, អនុវិស័យហិរញ្ញវត្ថុនីមួយៗ កាន់តែមានភាពប្រទាក់ក្រឡា និងស្មុគស្មាញ ដែលចាំបាច់តម្រូវឱ្យមានយន្តការក្របខ័ណ្ឌថ្នាក់ជាតិសមស្រប ដើម្បីឆ្លើយតបទៅនឹងហានិភ័យជាប្រព័ន្ធដែលអាចកើតមានឡើងជាយថាហេតុ ។

អង្គប្រជុំ បានវាយតម្លៃខ្ពស់អំពីសារៈសំខាន់នៃសេចក្ដីព្រាងឯកសារទាំងបី និងព្រមទាំងបានពិភាក្សាស៊ីជម្រៅលើខ្លឹមសារតាមផ្នែកនីមួយៗ ដើម្បីជាធាតុចូលបន្ថែមទៀតសម្រាប់ក្រុមការងារបន្តធ្វើការកែលម្អមុននឹងដាក់ស្នើសុំការសម្រេចពីរាជរដ្ឋាភិបាលកម្ពុជា ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី ប្រធានអង្គប្រជុំ ក៏បានថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ដល់ក្រុមការងារដែលបានខិតខំសហការរៀបចំឯកសារដ៏មានសារៈសំខាន់ទាំងបី និងបានណែនាំឱ្យក្រុមការងាររៀបចំឯកសារ និងក្រុមការងារអន្តរក្រសួងបន្តផ្ដល់កិច្ចសហការ និងធ្វើការផ្ទាល់ជាមួយអ្នកពាក់ព័ន្ធកែសម្រួលចំណុចដែលនៅខ្វះខាតតាមស្មារតីអង្គប្រជុំ ដើម្បីឱ្យឯកសារទាំងនេះកាន់តែមានលក្ខណៈពេញលេញនិងគ្រប់ជ្រុងជ្រោយ ។